# អត្ថប្រយោជន៍ការពារបន្ថែមជាក្រុម
# លើគ្រោះថ្នាក់ជាយថាហេតុ



## កម្មវត្ថុនៃការធានារ៉ាប់រង

អាយុជីវិតនៃសមាជិកដែលត្រូវបានធានា។

## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុសមាជិកដែលត្រូវបានធានា | 18 - 64ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 1ឆ្នាំ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $5,000 ឡើង |

## លក្ខខណ្ឌនៃការបង់បុព្វលាភ

| | |
|---|---|
| វិធីសាស្ត្របង់បុព្វលាភ | ដូចទៅនឹងផលិតផលមូលដ្ឋាន |
| មធ្យោបាយបង់បុព្វលាភ | ការផ្ទេរប្រាក់តាម App ឬគណនីធនាគារ សាច់ប្រាក់ មូលប្បទានបត្រ |
| ការបំពាន | ដូចទៅនឹងផលិតផលមូលដ្ឋាន |

## វិសាលភាពនៃការធានារ៉ាប់រង

ផលិតផលនេះធានាទៅលើមរណភាព ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងពិការភាពដោយផ្នែក និងជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុក្នុងអំឡុងពេលដែល អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមមានសុពលភាព។

## អត្ថប្រយោជន៍ធានារ៉ាប់រង

| | |
|---|---|
| សំណងមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ | ១០០% នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្តល់ជូន ក្នុងករណីសមាជិកដែលត្រូវបានធានាទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ |

| សំណងពិការភាពដោយផ្នែក និងជាអចិន្ត្រៃយ៍ ដោយគ្រោះថ្នាក់ជាយថាហេតុ | ភាគរយនៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្តល់ជូនដូចបង្ហាញក្នុងតារាងអត្ថប្រយោជន៍ធានារ៉ាប់រងខាងក្រោម ក្នុងករណីសមាជិកដែលត្រូវបានធានាទទួលរងពិការភាពដោយផ្នែក និងជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ |
|---|---|

## តារាងអត្ថប្រយោជន៍ធានារ៉ាប់រង

| ល.រ | ព្រឹត្តិការណ៍ត្រូវបានធានារ៉ាប់រង | ភាគរយ (%) នៃទឹកប្រាក់ត្រូវបានធានា |
|---|---|---|
| 1 | ការបាត់បង់អវយវៈ1 | 50% |
| 2 | ការបាត់បង់ដៃម្ខាងត្រឹមកដៃ | 50% |
| 3 | ការបាត់បង់ភ្នែកម្ខាង | 50% |
| 4 | ការបាត់បង់សមត្ថភាពក្នុងការស្តាប់លឺនៃត្រចៀកទាំងសងខាង | 75% |
| 5 | ការបាត់បង់សមត្ថភាពក្នុងការស្តាប់លឺនៃត្រចៀកម្ខាង | 20% |
| 6 | ការបាត់បង់សមត្ថភាពក្នុងការនិយាយ | 50% |
| 7 | ការបាត់បង់មេដៃ 2៖ ទាំង 2ថ្នាំងនៃមេដៃនីមួយៗ | 30% |
| 8 | ការបាត់បង់មេដៃ 1៖ ទាំង 2ថ្នាំង | 10% |
| 9 | ការបាត់បង់មេដៃ 1៖ តែ 1ថ្នាំង | 5% |
| 10 | ការបាត់បង់ចង្អុលដៃ 1៖ ទាំង 3ថ្នាំង | 6% |
| 11 | ការបាត់បង់ចង្អុលដៃ 1៖ ត្រឹម 2ថ្នាំង | 4% |
| 12 | ការបាត់បង់ចង្អុលដៃ 1៖ តែ 1ថ្នាំង | 2% |
| 13 | ការបាត់បង់ម្រាមកណ្តាល នាងដៃ ឬកូនដៃ 1៖ ទាំង 3ថ្នាំងនៃម្រាមណាមួយ | 5% |
| 14 | ការបាត់បង់ម្រាមកណ្តាល នាងដៃ ឬកូនដៃ 1៖ ត្រឹម 2ថ្នាំងនៃម្រាមណាមួយ | 3% |
| 15 | ការបាត់បង់ម្រាមកណ្តាល នាងដៃ ឬកូនដៃ 1៖ តែ 1ថ្នាំងនៃម្រាមណាមួយ | 2% |
| 16 | ការបាត់បង់មេជើង 1៖ ទាំង 2ថ្នាំង | 6% |
| 17 | ការបាត់បង់មេជើង 1៖ តែ 1ថ្នាំង | 2% |
| 18 | ការបាត់បង់ម្រាមជើងណាមួយផ្សេងទៀតក្រៅពីមេជើង (ក្នុងមួយម្រាម) | 3% |

*បញ្ជាក់៖ សំណងអតិបរមាសម្រាប់ពិការភាពដោយផ្នែក និងជាអចិន្ត្រៃយ៍ កំណត់ត្រឹម 100%នៃទឹកប្រាក់ត្រូវបានធានា ឬ ច្រើនបំផុត $100,000 សម្រាប់សមាជិកដែលត្រូវបានធានាមួយរូប។

ចំណាំ៖ ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា សូមអានខ និងលក្ខខណ្ឌធានារ៉ាប់រង។

## ករណីមិនធានា

ក្រុមហ៊ុននឹងមិនធានាលើករណីមរណភាព ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងពិការភាពដោយផ្នែក និងជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ ដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោមឡើយ៖

(១) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។
(២) ការឆ្លងវីរុសហ៊ីវ (HIV) រោគសញ្ញានៃជំងឺអេដស៍ ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។
(៣) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ការធ្វើកូដកម្ម ការកើនឡើងប្រជាប្រិយភាពប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។
(៤) ខណៈពេលដែលសមាជិកដែលត្រូវបានធានាប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលសមាជិកដែលត្រូវបានធានាកំពុងត្រូវបានចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។
(៥) ការធ្វើដំណើរចូល ការចាកចេញ ការប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីសមាជិកដែលត្រូវបានធានាគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយដែលធ្វើការ ហោះហើរជាប្រចាំ និងទៀងទាត់តាមកាលវិភាគហោះហើរ និងគន្លងធ្វើដំណើរផ្លូវអាកាសដែលបានកំណត់របស់ក្រុមហ៊ុន។
(៦) ខណៈពេលដែលសមាជិកដែលត្រូវបានធានាបំពេញកាតព្វកិច្ចជាយោធា ប៉ូលីស ឬជាអ្នកស្ម័គ្រចិត្តចូលរួមក្នុងសង្គ្រាម ឬការបង្ក្រាបឧក្រិដ្ឋកម្ម។
(៧) សមាជិកដែលត្រូវបានធានាបានដឹងអំពីបញ្ហារាងកាយថាមានជំងឺ ឬរបួសមុនពេលចាប់ផ្តើមកិច្ចសន្យាធានារ៉ាប់រង ប៉ុន្តែសមាជិកដែលត្រូវបានធានាមិនបានជូនដំណឹងដល់ក្រុមហ៊ុនឡើយ។
(៨) សមាជិកដែលត្រូវបានធានាស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណចុះបញ្ជីត្រឹមត្រូវ។
(៩) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។
(១០) ការមានគភ៌ ការសម្រាលកូន ការរលូតកូន ឬផលវិបាកណាមួយកើតចេញពីកត្តាទាំងអស់នេះ។